# Vacancy Announcement

FTB
ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា
Foreign Trade Bank of Cambodia

## ដំណឹងជ្រើសរើសបុគ្គលិក

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា (FTB) គឺជាធនាគារពាណិជ្ជក្នុងស្រុកទី១ នៅកម្ពុជាដែលទទួលបានការទុកចិត្តចាប់តាំងពីឆ្នាំ១៩៧៩ ។ ធនាគារ FTB បានផ្តល់ជូនអតិថិជននូវសេវាហិរញ្ញវត្ថុប្រកបដោយភាពជឿទុកចិត្ត និងសុវត្ថិភាពខ្ពស់ក្នុងធុរកិច្ចរបស់ខ្លួន ។ ផ្អែកលើចក្ខុវិស័យ ជាធនាគារពាណិជ្ជដែលមានការពេញចិត្តជាងគេក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារ FTB ប្តេជ្ញាបន្តគាំទ្រធុរកិច្ចរបស់អតិថិជនឲ្យកាន់តែរីកចម្រើនលូតលាស់ និងផ្តល់ជូនគ្រប់បុគ្គលិកនូវឱកាសអាជីពការងារ ដែលមានស្ថិរភាពយូរអង្វែងផងដែរ ។ ធនាគារកំពុងបន្តពង្រីកនូវវិសាលភាពប្រតិបត្តិការរបស់ខ្លួន និងពង្រឹងសមត្ថភាពបុគ្គលិកដើម្បីជួយទ្រទ្រង់នូវការរីកចម្រើនប្រកបដោយចីរភាពយូរអង្វែង។ ទន្ទឹមនឹងការពង្រីកប្រតិបត្តិការនេះធនាគារយើងខ្ញុំ កំពុងស្វែងរកនូវបេក្ខភាពដែលមានគុណវុឌ្ឍិ និងឆន្ទៈខ្ពស់ ដើម្បីចូលរួមជាមួយធនាគារ FTB "**និយោជកដ៏ប្រសើរនិងឈានមុខ**" សម្រាប់មុខងារខាងក្រោម៖

### បុគ្គលិកផ្នែកថែទាំអតិថិជន -វេនធម្មតា / វេនពេលយប់ (ចំនួន ០២នាក់ បម្រើការនៅការិយាល័យកណ្តាល ភ្នំពេញ)

មុខតំណែងនេះទទួលខុសត្រូវទៅលើការឆ្លើយតបតាមប្រព័ន្ធទូរស័ព្ទ ដោយឆ្លើយតបរាល់ចំងល់ និងបញ្ហាផ្សេងៗរបស់អតិថិជន ដើម្បីផ្តល់សេវាកម្មល្អ សមស្របតាមតម្រូវការរបស់ពួកគាត់ ប្រកបដោយគុណភាព និងប្រសិទ្ធភាព ។

### ការទទួលខុសត្រូវចម្បងៗ

- ឆ្លើយតបការហៅទូរស័ព្ទរបស់អតិថិជនប្រកបដោយវិជ្ជាជីវៈ និងបំពេញតាមតម្រូវការរបស់អតិថិជនបានរហ័ស និងទាន់ពេលវេលា
- ទទួលខុសត្រូវរាល់តម្រូវការ និងដោះស្រាយរាល់បញ្ហារបស់អតិថិជន
- ផ្តល់ព័ត៌មានជូនអតិថិជនអំពីសេវាកម្ម និងផលិតផលរបស់ធនាគារ
- ផ្តល់សេវាកម្មល្អ និងដំណោះស្រាយជូនអតិថិជន ឱ្យល្អប្រសើរបំផុត
- កំណត់បាន គ្រប់គ្រង និងវាស់វែង ទៅលើអាទិភាពនៃបញ្ហា
- រៀបចំរបាយការណ៍ និងរាយការណ៍ជូនថ្នាក់គ្រប់គ្រងឱ្យបានទាន់ពេលវេលា
- បង្កើត និងរក្សាទំនាក់ទំនងល្អជូនអតិថិជន ប្រកបដោយការទទួលខុសត្រូវខ្ពស់
- សិក្សា និងស្វែងយល់ឱ្យបានច្បាស់ទៅលើព័ត៌មានអំពីសេវាកម្ម និងផលិតផល សម្រាប់ឆ្លើយតបជូនអតិថិជនប្រកបដោយទំនុកចិត្ត
- អនុវត្តការងារផ្សេងៗទៅតាមការចាត់តាំងរបស់ថ្នាក់គ្រប់គ្រង

### លក្ខណៈសម្បត្តិ និងបទពិសោធន៍

- ថ្នាក់បរិញ្ញាបត្រ ផ្នែកធនាគារ និងហិរញ្ញវត្ថុ ឬជំនាញដែលពាក់ព័ន្ធ
- មានបទពិសោធន៍យ៉ាងតិច ១ឆ្នាំ ផ្នែកទំនាក់ទំនង ឬផ្នែកថែទាំអតិថិជន ក្នុងវិស័យធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ
- មានចំណេះដឹងខ្ពស់ទាំងគោលការណ៍ ទាំងការអនុវត្តផ្នែកសេវាកម្មអតិថិជន
- មានជំនាញទំនាក់ទំនងតាមប្រព័ន្ធទូរស័ព្ទ (Avaya System) និងបច្ចេកទេស
- មានជំនាញក្នុងការដោះស្រាយបញ្ហា អាចសម្របបានគ្រប់ស្ថានការណ៍ និងភាពផ្សេងៗគ្នារបស់មនុស្ស
- មានភាពស្មោះត្រង់ សុចរិតភាព មានការអត់ធ្មត់ខ្ពស់ ទំនួលខុសត្រូវខ្ពស់ និងហ្មត់ចត់ក្នុងការងារ
- មានជំនាញអន្តរបុគ្គល និងជំនាញទំនាក់ទំនងទាំងក្នុង និងក្រៅស្ថាប័ន
- មានចំណេះដឹងភាសាអង់គ្លេស និងអាចប្រើប្រាស់កុំព្យូទ័របានស្ទាត់ជំនាញ (Microsoft Office Word & Excel)

### របៀបដាក់ពាក្យ

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមអញ្ជើញផ្ញើប្រវត្តិរូបសង្ខេប (មានបិទរូបថត) ជាមួយលិខិតអមជាភាសាខ្មែរ/អង់គ្លេសមកធនាគារតាមរយៈ អ៊ីម៉ែលៈ HR@ftbbank.com ឬការិយាល័យកណ្តាល ស្ថិតនៅអគារលេខ ៣៣C-D ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ឬតាមសាខាណាមួយ របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ។ មានតែបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងត្រូវបានជាប់ក្នុងបញ្ជីសម្រាំង និងត្រូវបានទូរស័ព្ទអញ្ជើញឲ្យមកចូលសម្ភាសន៍ ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់លេខទូរសព្ទ: ០៨១ ៦៦៦ ៥៩៧/ ០៨១ ៦៦៦ ៥៣៥

☎ : 023 862 111
E-mail: hr@ftbbank.com
www.ftbbank.com
f : www.facebook.com/ftbcambodia

វិនិយោគដើម្បីអនាគត
Investing in the future